**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
**Ministry of Environment**
លេខ: ២៧២ សជណ បស្ត.អកធ

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មិថុនា ឆ្នាំ ២០០៩

**សូមជម្រាបជូន**
**ឯកឧត្តម ប្រធានយន្តការប្រតិកម្មរហ័ស ទីស្តីការគណៈរដ្ឋមន្ត្រី**

**កម្មវត្ថុ:** ករណីពាក់ព័ន្ធ និងការចុះផ្សាយព័ត៌មានរបស់កាសែតរស្មីកម្ពុជា លេខ ៤៩០៨ ឆ្នាំទី ១៧ ចុះថ្ងៃទី ៣១-០១ ខែ ឧសភា-មិថុនា ឆ្នាំ ២០០៩ ក្រោមចំណងជើងថា “ បទល្មើសព្រៃឈើក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព កើត មានរាល់ថ្ងៃ និងកាន់តែធ្ងន់ធ្ងរ “ ។

**យោង:**-អត្ថបទសារព័ត៌មានរបស់កាសែតរស្មីកម្ពុជាលេខ ៤៩០៨ ឆ្នាំទី១៧ ចុះថ្ងៃទី ៣១-០១ ខែ ឧសភា-មិថុនា ឆ្នាំ ២០០៩

-លិខិតលេខ ០៣៤ ដគព្រ.អកធ.បស្ត ចុះថ្ងៃទី០១ ខែ មិថុនា ឆ្នាំ ២០០៩ របស់ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ភូមិសាស្ត្រ ខេត្តព្រះវិហារ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា: យោងអត្ថបទកាសែតរស្មីកម្ពុជា លេខ ៤៩០៨ ឆ្នាំទី១៧ ចុះផ្សាយថ្ងៃអាទិត្យ-ច័ន្ទ ទី៣១-០១ ខែ ឧសភា ឆ្នាំ ២០០៩ ក្រោមចំណងជើងថា “ បទល្មើស ព្រៃឈើក្នុងដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេពកើតមានរាល់ថ្ងៃ និងកាន់តែធ្ងន់ធ្ងរ ” នោះជាការមិនពិតទេ ព្រោះ ចំនុចកោះត្នោយនេះ កំលាំងមន្ត្រីឧទ្យានុរក្ស តែងតែសហការជាមួយកំលាំងសមត្ថកិច្ចពាក់ព័ន្ធចុះបង្ក្រាបបទល្មើស ធនធានធម្មជាតិជាបន្តបន្ទាប់ ។ ហើយរាល់ការបង្ក្រាបនេះទៀត គឺតែងតែធ្វើឡើងក្រោមកិច្ចសហការ ធ្វើឡើងក្រោមកិច្ចសហការ និងចុះជាប់ជានិច្ចរបស់ទីប្រឹក្សាបច្ចេកទេស នៃអង្គការសមាគមន៍ អភិរក្សសត្វព្រៃ កម្ពុជា WCS ដែលជាអង្គការជួយឧបត្ថម្ភទាំង ផ្នែកថវិកា និងផ្នែកបច្ចេកទេសដល់ដែនជម្រក សត្វព្រៃគូលែន-ព្រហ្មទេពភូមិសាស្ត្រខេត្តព្រះវិហារ ។ជាក់ស្តែងដូចនៅថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០០៩ មន្ត្រីឧទ្យានុរក្សបានសហការជាមួយកំលាំងនៃ ស្នងការនគរបាល ខេត្តព្រះវិហារ បានចុះរុះរើខ្ទមអនាធិបតេយ្យ ចំនួន ០២ខ្ទម នៅចំនុចកោះត្នោយ ស្ថិតនៅក្នុងភូមិសាស្ត្រ ឃុំប៉ាលហាល ស្រុកត្បែងមានជ័យ និងរឹបអូសបាន សត្វឈ្លូស ០២ក្បាល និងដុតបំផ្លាញស្នាតេះចំនួន ០២ដើម ព្រមទាំងឱ្យជនល្មើសធ្វើកិច្ចសន្យាបញ្ឈប់សកម្មភាព ល្មើស ធនធានធម្មជាតិតទៅទៀត ។

ម្យ៉ាងទៀត ការចេញផ្សាយអត្ថបទនេះ បានកើតមានឡើងក្រោយពីលោកនាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ខេត្តព្រះវិហារ បានទទួលទូរស័ព្ទពីមនុស្សមួយចំនួនដែលបានអះអាងថាមកពីសមាគមន៍សារព័ត៌មាន

និងអ្នកខ្លះថាជាអ្នក យកសារព័ត៌មានប្រចាំកាសែតឈ្មោះនេះឈ្មោះនោះ បានទូរស័ព្ទមកជំរិតទារប្រាក់ពីរូបគាត់ ដើម្បីយកទៅដោះស្រាយ មធ្យោបាយធ្វើដំណើរទៅប្រជុំនៅភ្នំពេញ ហើយខ្លះបានទូរស័ព្ទមកទារប្រាក់ថាយកទៅជប់លៀងជាមួយមេៗ ដោយការជំរិត ទារប្រាក់នេះម្តងៗ មានចំនួនចាប់ពី ១០០ដុល្លា ( មួយសន្លឹក ) ឡើងទៅតែលោកនាយកបានប្រាប់វិញថា ប្រាក់ខែ របស់គាត់មិនទាំងគ្រប់នឹងចំនួនទារនេះផង ដូចនេះមិនមានប្រាក់ឯណាសម្រាប់ឱ្យអស់លោកបានទេ ទាំងនេះគឺជាដើម ចមធ្វើឱ្យអ្នកទាំងនោះរកមធ្យោបាយចុះកាសែតបំភ្លើសការពិតជាក់ស្តែងនៅក្នុងតំបន់ ។

ហេតុដូចនេះ ខ្លឹមសារព័ត៌មានដែលបានចុះផ្សាយ ថ្ងៃអាទិត្យ-ច័ន្ទទី ៣១-០១ ខែ ឧសភា-មិថុនា ឆ្នាំ២០០៩ គឺជា ព័ត៌មានបំភ្លើសការពិត ហើយការចុះនេះទៀតសោតកើតចេញពីការដែលអ្នកយកព័ត៌មានទាំងនោះជំរិតទារប្រាក់ពីលោកនាយកដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេពភូមិសាស្ត្រខេត្តព្រះវិហារ មិនបានសម្រេច ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបតាមការគួរ ។
សូមឯកឧត្តមទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

បណ្ឌិត. ជីវវិទ្យា

**ចម្លងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងព័ត៌មាន
- សាលាខេត្តព្រះវិហារ
- អគ្គនាយកដ្ឋានរដ្ឋបាលការពារ និង អភិរក្សធម្មជាតិ
- ដែនជម្រកសត្វព្រៃគូលែន-ព្រហ្មទេព ខេត្តព្រះវិហារ
- ឯកសារ-កាលប្បវត្តិ

វាយអត្ថបទដោយៈ លោក ផាត់ ផ្លារ៉ា